**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

Ministry of Labour and Vocational Training

លេខ : ១៨៤ ក.ប/ស.ជ.៣.គ.ប.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការសិក្សាស្រាវជ្រាវអំពី "ស្ថានភាពជីវភាពរស់នៅរបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន **លោក លោកស្រីជាម្ចាស់ ឬអ្នកតំណាងរោងចក្រ សហគ្រាស** ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** ទាំងអស់ មេត្តាជ្រាបថា លេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងធ្វើការសិក្សាស្រាវជ្រាវស្តីពី "**ស្ថានភាពជីវភាពរស់នៅបច្ចុប្បន្ន របស់កម្មករនិយោជិត ដែលបម្រើការងារក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា**" ដោយមាន "**វិទ្យាស្ថានជាតិស្ថិតិ**" ជាអ្នកទទួលបន្ទុកចុះអង្កេតប្រមូលទិន្នន័យ។ ការធ្វើអង្កេតនេះ នឹងចាប់អនុវត្តចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ទៅលើគំរូកម្មករនិយោជិតចំនួន ១ ៥០០នាក់ និងរោងចក្រចំនួន ៧៥រោងចក្រ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។

អាស្រ័យដូចបានជម្រាបជូនខាងលើ **សូម លោក លោកស្រីជាម្ចាស់ ឬអ្នកតំណាងរោងចក្រ សហគ្រាស** ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** ទាំងអស់ មេត្តាជ្រាប និងផ្តល់កិច្ចសហការជាមួយលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ និងជាមួយក្រុមការងាររបស់វិទ្យាស្ថានជាតិស្ថិតិក្នុងការចុះធ្វើអង្កេតនេះ។

សូម **លោក លោកស្រីជាម្ចាស់ ឬអ្នកតំណាងរោងចក្រ សហគ្រាស** ក្នុងវិស័យខាងលើ និង**អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ** មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**